**វិទ្យាស្ថានសភាកម្ពុជា**
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ២០១៩**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺៈ

- ការនាំចេញអង្ករបស់កម្ពុជានៅទ្រឹងក្នុងឆ្នាំ២០១៨ ប៉ុន្តែនឹងមានការគាំទ្រពីចិន និងវៀតណាម សម្រាប់ឆ្នាំ២០១៩
- គោលនយោបាយសារពើពន្ធរបស់ប្រទេសសិង្ហបុរី ជះឥទ្ធិពលដល់អត្រាការប្រាក់នាពេលខាងមុខ
- សហរដ្ឋអាមេរិកស្នើចិនកុំបន្ទាបតម្លៃប្រាក់យ៉ន់ ដើម្បីទប់ទល់នឹងសម្ពាធពាណិជ្ជកម្ម

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗ នៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តន៍នៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ការនាំចេញអង្កររបស់កម្ពុជាមានលក្ខណៈថេរក្នុងឆ្នាំ២០១៨ ប៉ុន្តែនឹងមានការគាំទ្រពីចិន និងវៀតណាម ក្នុងឆ្នាំ២០១៩

យោងតាមទិន្នន័យចុងក្រោយរបស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បានបង្ហាញថា ការនាំចេញអង្កររបស់កម្ពុជា មានចំនួន ៦២៦ ២២៥តោន នៅក្នុងឆ្នាំ២០១៨ ដែលធ្លាក់ចុះចំនួន១,៥% បើធៀបទៅនឹងឆ្នាំ២០១៧ ដែលមានចំនួន ៦៣៥ ៦៧៩តោន។

ឧស្សាហកម្មនេះ ត្រូវបានគេរំពឹងថាអាចនឹងជួបបញ្ហាប្រឈមមួយចំនួននៅឆ្នាំ២០១៩ ដូចជា ការដាក់ពន្ធនាំចូលពីសំណាក់សហភាពអឺរ៉ុបដែលជាទីផ្សារនាំចេញអង្ករធំបំផុតរបស់កម្ពុជា ការប្រឈមនឹងថ្លៃដើមផលិតកម្មខ្ពស់ និងកង្វះខាតផ្នែកគុណភាពហេដ្ឋារចនាសម្ព័ន្ធ។ ទោះជាយ៉ាងណាក៏ដោយ អ្នកជំនាញក្នុងឧស្សាហកម្មនេះ ដូចជាអ្នកជំនាញនៅក្នុងសហព័ន្ធស្រូវអង្ករកម្ពុជា រំពឹងថាកំណើនកូតាសម្រាប់ពាណិជ្ជកម្មជាមួយប្រទេសចិន និងវៀតណាម នឹងបង្កើនតម្រូវការអង្កររបស់កម្ពុជានៅក្នុងឆ្នាំ២០១៩ និងទប់ស្កាត់មិនអោយមានការធ្លាក់ចុះដូចក្នុងឆ្នាំ២០១៨ កន្លងមក។

### តារាងប្រចាំសប្តាហ៍៖ បញ្ញើជាប្រាក់រៀលនៅធនាគារ

តារាងសប្តាហ៍នេះ បង្ហាញពីទិន្នន័យប្រាក់បញ្ញើជាប្រាក់រៀលនៅក្នុងធនាគារ ពីខែកញ្ញា ឆ្នាំ២០១៤ ដល់ខែកញ្ញា ឆ្នាំ២០១៨។ ទិន្នន័យបង្ហាញថា ប្រាក់បញ្ញើមានកាលកំណត់ មានចំនួន ១៤ ៤៤០ ប៊ីលានរៀល ក្នុងខែកញ្ញា ឆ្នាំ២០១៨ ដែលកើនពី ៤ ៩៣៦ ប៊ីលានរៀល នៅក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ពោលគឺកើនឡើង១៩៦%។ បញ្ញើចរន្ត និងបញ្ញើសន្សំ ក៏បានកើនឡើងក្នុងកម្រិតប្រហាក់ប្រហែលគ្នាដែរ។

**បញ្ញើជាប្រាក់រៀលនៅធនាគារ (គិតជាប៊ីលានរៀល)**




ប្រភព៖ របាយការណ៍ធនាគារជាតិនៃកម្ពុជា

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### គោលនយោបាយសារពើពន្ធរបស់ប្រទេសសឹង្ហបុរី ជះឥទ្ធិពលដល់អត្រាការប្រាក់នាពេលខាងមុខ

ក្រុមសេដ្ឋវិទូបានហៅការសម្រេចចិត្តទៅលើគោលនយោបាយនៅខែមេសាខាងមុខរបស់ធនាគារកណ្តាលរបស់ប្រទេសសឹង្ហបុរីថានឹងមានឥទ្ធិពលពីរ គឺឥទ្ធិពលវិជ្ជមានទៅលើគោលនយោបាយសារពើពន្ធ និង ឥទ្ធិពលអវិជ្ជមានដល់ហានិភ័យខាងក្រៅ។

បើសិនមិនមានអ្វីប្រែប្រួល កំណើនសេដ្ឋកិច្ចប្រកបដោយស្ថេរភាព និងការកើនឡើងនូវចំណាយសារពើពន្ធរបស់ប្រទេសសឹង្ហបុរី នឹងជំរុញឱ្យអាជ្ញាធររូបិយវត្ថុរបស់សឹងង្ហបុរីបន្តតម្លើងអត្រាការប្រាក់ ដូចអ្វីដែលខ្លួនបានធ្វើក្នុងការសម្រេចចិត្តដែលបានគ្រោងទុកនៅក្នុងឆ្នាំ២០១៨។ ទោះជាយ៉ាងណាក៏ដោយ ការកើនឡើងនេះ បានថយចុះ ដោយសារការកើនឡើងនូវហានិភ័យជាសកល ហើយមានមនុស្សជាច្រើនកំពុងរំពឹងថាធនាគារនឹងប្រើប្រាស់វិធី "រង់ចាំមើល"។

អាជ្ញាធររូបិយវត្ថុរបស់ប្រទេសសឹង្ហបុរី គឺមានលក្ខណៈពិសេស នៅក្នុងចំណោមបណ្តាប្រទេសជឿនលឿន ដោយអនុវត្តគោលនយោបាយរូបិយវត្ថុ តាមរយៈការកំណត់អត្រាប្តូរប្រាក់ ធៀបទៅនឹងកញ្ចប់រូបិយបណ្ណរបស់ដៃគូពាណិជ្ជកម្មរបស់ខ្លួន ជាជាងការកំណត់អត្រាការប្រាក់។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### សហរដ្ឋអាមេរិកស្នើចិនកុំបន្ទាបតម្លៃប្រាក់យ៉ន់ដើម្បីទប់ទល់នឹងសម្ពាធពាណិជ្ជកម្ម

យោងតាមទីភ្នាក់ងារសារព័ត៌មាន Bloomberg បានឱ្យដឹងថា សហរដ្ឋអាមេរិកកំពុងស្នើចិនរក្សាតម្លៃប្រាក់យ៉ន់ឱ្យនៅថេរ ដែលនេះជាផ្នែកមួយនៃការចរចារពាណិជ្ជកម្ម។ ប្រសិនបើសំណើនេះត្រូវបានយល់ព្រមពីភាគីចិន សំណើនេះនឹងត្រូវបានដាក់ក្នុងអនុស្សរណៈនៃការយោគយល់គ្នា ប៉ុន្តែព័ត៌មានលម្អិតនៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ។

មន្ត្រីរបស់ភាគីទាំងពីរ បានជួបគ្នាដើម្បីពិភាក្សារកដំណោះស្រាយមួយទៅលើសង្គ្រាមពាណិជ្ជកម្មរវាងប្រទេសមហាអំណាចសេដ្ឋកិច្ចធំៗទាំងពីររបស់ពិភពលោក។ ប្រធានាធិបតីអាមេរិក លោក Donald Trump បានចោទប្រកាន់ ជាញឹកញាប់ទៅភាគីចិន ថាបានប្រើប្រាស់វិធីសាស្ត្រប្រែប្រួលតំលៃរូបិយបណ្ណរបស់ខ្លួន ដើម្បីទាញយកប្រយោជន៍ពីពលរដ្ឋអាមេរិក។ កិច្ចប្រជុំបន្ទាប់ត្រូវបានគ្រោងធ្វើនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៩។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

សប្តាហ៍ខាងមុខនេះ ប្រទេសក្នុងតំបន់អាស៊ីភាគច្រើន នឹងបង្ហាញស្ថិតិអតិផរណា ហើយប្រទេសមួយចំនួន ដូចជាហុងកុង និងកូរ៉េខាងត្បូង នឹងធ្វើការសម្រេចទៅលើអត្រាការប្រាក់។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

ថ្ងៃចន្ទ ទី២៥ ខែកុម្ភៈ ២០១៩

- តុល្យភាពថវិការបស់ហ្វីលីពីន សម្រាប់ខែធ្នូ
- ការសម្រេចអត្រាការប្រាក់របស់ហុងកុង
- សន្ទស្សន៍នៃភាពជឿជាក់របស់ជប៉ុន សម្រាប់ខែធ្នូ
- អតិផរណារបស់សឹង្ហបុរី សម្រាប់ខែមករា

ថ្ងៃអង្គារ ទី២៦ ខែកុម្ភៈ ២០១៩

- ភាពជឿជាក់របស់អ្នកប្រើប្រាស់របស់កូរ៉េខាងត្បូង សម្រាប់ខែកុម្ភៈ
- ផលិតកម្មឧស្សាហកម្មរបស់សឹង្ហបុរី សម្រាប់ខែមករា
- តុល្យភាពពាណិជ្ជកម្មរបស់ហុងកុង សម្រាប់ខែមករា
- និកម្មភាពរបស់ថៃ សម្រាប់ខែមករា
- ផលិតកម្មឧស្សាហកម្មរបស់ ថៃ សម្រាប់ខែមករា

ថ្ងៃពុធ ទី២៧ ខែកុម្ភៈ ២០១៩

- ភាពជឿជាក់ទៅលើពាណិជ្ជកម្មរបស់កូរ៉េខាងត្បូង សម្រាប់ខែកុម្ភៈ
- ប្រាក់ចំណេញឧស្សាហកម្មរបស់ចិន សម្រាប់ខែមករា
- ផសស របស់ហុងកុងសម្រាប់ត្រីមាសទី៤ ឆ្នាំ ២០១៨
- កិច្ចប្រជុំរវាងអាមេរិក និងកូរ៉េខាងជើង

ថ្ងៃព្រហស្បតិ៍ ទី២៨ ខែកុម្ភៈ ២០១៩

- ការលក់រាយរបស់កូរ៉េខាងត្បូង សម្រាប់ខែមករា
- ការវិនិយោគមូលបត្ររបស់ជប៉ុន សម្រាប់២៣/កុម្ភៈ
- ការសម្រេចអត្រាការប្រាក់របស់កូរ៉េខាងត្បូង
- ផលិតកម្មឧស្សាហកម្មរបស់វៀតណាម សម្រាប់ខែកុម្ភៈ
- អត្រាអតិផរណារបស់វៀតណាម សម្រាប់ខែកុម្ភៈ
- តុល្យភាពពាណិជ្ជកម្មរបស់វៀតណាម សម្រាប់ខែកុម្ភៈ
- ការលក់រាយរបស់ថៃ សម្រាប់ខែធ្នូ

ថ្ងៃសុក្រ ទី០១ ខែមីនា ២០១៩

- និកម្មភាពរបស់ ជប៉ុន សម្រាប់ខែមករា
- តុល្យភាពពាណិជ្ជកម្មរបស់កូរ៉េខាងត្បូងសម្រាប់ខែកុម្ភៈ
- សន្ទស្សន៍ថ្លៃអ្នកផលិតរបស់ហ្វីលីពីន សម្រាប់ខែមករា
- អតិផរណារបស់ថៃ សម្រាប់ខែកុម្ភៈ
- អតិផរណារបស់ឥណ្ឌូនេស៊ី សម្រាប់ខែកុម្ភៈ